ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៣៩២៥ អយក.ជាវ

ថ្ងៃសុក្រ ១០កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩

**ជម្រាបមក**

**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាទាំង២៥ រាជធានី ខេត្ត**

**លោក លោកស្រីប្រធានការិយាល័យ អយក ក្រុង ស្រុក ខណ្ឌគោលដៅទាំង៨៩**

**លោកនាយក នាយិកាសាលារៀនគោលដៅទាំង១០០**

**កម្មវត្ថុៈ** គោលការណ៍ណែនាំបន្ថែមស្តីពីការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈសម្រាប់គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP)។

**យោងៈ** -កិច្ចព្រមព្រៀងឥណទានសម្បទាន IDA No.5978-KH ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារពិភពលោក

-គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ

-លិខិតលេខ ៣៤៩២ អយក.ហវ ចុះថ្ងៃសុក្រ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈសម្រាប់ឆ្នាំ២០១៩ នៃគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា(SEIP) ចុះថ្ងៃសុក្រ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី ប្រធាន លោកនាយក នាយិកាសាលាគោលដៅ ជ្រាបថាៈ ក្នុងឆ្នាំ២០១៩ នេះ គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា បានផ្ទេរថវិកាហិរញ្ញប្បទានដោយភ្ជាប់សូចនាករ(DLI) សម្រាប់មូលនិធិដំណើរការសាលារៀនទៅឲ្យអង្គភាពគោលដៅរួមមានៈ មន្ទីរអយក.ទាំង២៥ រាជធានីខេត្ត ការិយាល័យ អយក. ក្រុង ស្រុក ខណ្ឌគោលដៅចំនួន ៨៩ និងសាលារៀនគោលដៅចំនួន ១០០ ។

ដូចនេះ ដើម្បីធានាបានការអនុវត្តថវិកាឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា សូមធ្វើការណែនាំបន្ថែមលើការអនុវត្តថវិកាដូចខាងក្រោមៈ

**១-ថ្នាក់សាលារៀនៈ**

- **នីតិវិធីនៃការអនុវត្តថវិកាៈ** ត្រូវអនុវត្តថវិកាតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់មូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) និងអនុវត្តថវិកា ចាប់ផ្តើមពីថវិកាមានក្នុងគណនី របស់សាលារៀនគោលដៅនីមួយៗ ចំពោះថវិកានៅសល់ក្នុងឆ្នាំត្រូវបន្តអនុវត្តនៅឆ្នាំបន្ទាប់ ។
- **មុខសញ្ញាចំណាយៈ** ចំពោះមុខចំណាយដែលត្រូវអនុវត្តត្រូវផ្អែកលើផែនការសកម្មភាពនៃផែនការកែលម្អសាលារៀន និងផែនការថវិកាដែលសាលារៀននីមួយៗបានរៀបចំជាមួយគ្រូបង្គោលថ្នាក់ជាតិនៃគម្រោង SEIP តាមស្តង់ដារទាំង៩ លើគោលការណ៍ស្តីពីការគ្រប់គ្រងតាមសាលារៀន



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

(SBM) ដោយផ្តោតលើផែនការ សកម្មភាពជាអាទិភាព ដែលសាលារៀនមានសិទ្ធិស្វ័យភាពក្នុងការអនុវត្តដោយសំដៅលើការកែលម្អគុណភាពអប់រំនៅតាមសាលារៀននីមួយៗ។

- **កិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍៖** ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់មូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ហើយរបាយការណ៍ត្រូវផ្ញើទៅការិយាល័យ អយក តាមកាលកំណត់ជាក់លាក់។
- **សក្ខីប័ត្រគាំទ្រការអនុវត្តថវិកា៖** ត្រូវរក្សាទុកតាមសាលារៀនគោលដៅនីមួយៗ សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម។

**២-ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ៖**

- **នីតិវិធីនៃការអនុវត្តថវិកា៖** ការអនុវត្តថវិកាត្រូវផ្អែកលើនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ថវិការដ្ឋ និងអនុវត្តថវិកា ចាប់ផ្តើមពីថវិកាមានក្នុងគណនី របស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗ ចំពោះថវិកានៅសល់ក្នុងឆ្នាំត្រូវបន្តអនុវត្តនៅឆ្នាំបន្ទាប់ ។
- **មុខសញ្ញាចំណាយ៖** ចំពោះមុខសញ្ញាចំណាយត្រូវផ្អែកលើផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដោយផ្តោតលើការពិនិត្យតាមដានក្នុងការពង្រឹងលើការអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងតាមសាលារៀន(SBM) ហើយការចំណាយទាំងនេះត្រូវអនុលោមតាមលិខិតលេខ៧៧៧៨ សហវ. អថ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ និងលិខិតលេខ ៣៦០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩
- **កិច្ចបញ្ជិកាគណនេយ្យ៖** ការអនុវត្តកិច្ចបញ្ជិកាដូចការអនុវត្តសម្រាប់ថវិការដ្ឋដែរ និងត្រូវមានប័ណ្ណចំណូល ប័ណ្ណចំណាយ និងបញ្ជីបេឡា ដោយឡែកពីថវិការដ្ឋ។
- **របាយការណ៍៖** ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋ និងផ្ញើមកអង្គភាពហិរញ្ញវត្ថុ គម្រោងមួយច្បាប់សម្រាប់រក្សាទុកជាឯកសារ។
- **ប្រាក់ឧបត្ថម្ភបេសកកម្ម និងសក្ខីប័ត្រ៖**

  *ប្រាក់ឧបត្ថម្ភចំនួន ៤០០០០៛០០(សែសិបពាន់រៀលគត់) ក្នុងមួយនាក់ក្នុងមួយថ្ងៃសម្រាប់មន្ត្រីអប់រំចុះតាមដានការងារបច្ចេកទេសនៅតាមសាលារៀន ដែលស្ថិតក្នុងរង្វង់ក្រុង ស្រុក ខណ្ឌ។

  *សក្ខីប័ត្រ៖

  -ត្រូវមានលិខិតឧទ្ទេសនាម ដោយមិនចាំបាច់ប្រើប្រាស់ទិដ្ឋាការ ប៉ុន្តែត្រូវមានការបញ្ជាក់ពីអ្នកទទួលខុសត្រូវនៅទីតាំងដែលបានទៅដល់លើលិខិតឧទ្ទេសនាម

  -តារាងទូទាត់ប្រាក់ឧបត្ថម្ភ និងរបាយការណ៍សកម្មភាព។
- **សក្ខីប័ត្រគាំទ្រការអនុវត្តថវិកា៖** ត្រូវរក្សាទុកនៅការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម។

**៣-ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា៖**

- **នីតិវិធីនៃការអនុវត្តថវិកា៖** ការអនុវត្តថវិកាត្រូវផ្អែកលើនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋ និងអនុវត្តថវិកា ចាប់ផ្តើមពីថវិកាមានក្នុងគណនី របស់មន្ទីរអប់រំ យុវជន និងកីឡានីមួយៗ ចំពោះថវិកានៅសល់ក្នុងឆ្នាំត្រូវបន្តអនុវត្តនៅឆ្នាំបន្ទាប់ ។
- **មុខសញ្ញាចំណាយ៖** ចំពោះមុខចំណាយត្រូវផ្អែកលើផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដោយផ្តោតលើការពិនិត្យតាមដាន ក្នុងការអនុវត្តរបស់ថ្នាក់ស្រុកក្នុងការពង្រឹងលើការអនុវត្តគោល

ការណ៍ស្តីពីការគ្រប់គ្រងតាមសាលារៀន(SBM) ហើយការចំណាយទាំងនេះត្រូវអនុលោមតាមអនុក្រឹត្យលេខ ២១៦.អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២១៤ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

•**កិច្ចបញ្ជិកាគណនេយ្យ៖** ការអនុវត្តកិច្ចបញ្ជិកាតាមការអនុវត្តកិច្ចបញ្ជិកាសម្រាប់ថវិការដ្ឋ និងត្រូវមានប័ណ្ណចំណូល ប័ណ្ណចំណាយ និងបញ្ជីបេឡា ដោយឡែកពីថវិការដ្ឋ

•**របាយការណ៍៖** ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋ និងផ្ញើមកអង្គភាពហិរញ្ញវត្ថុគម្រោងមួយច្បាប់សម្រាប់រក្សាទុកជាឯកសារ។

•**ប្រាក់ឧបត្ថម្ភបេសកកម្ម និងសក្ខីប័ត្រ៖**

*ប្រាក់ឧបត្ថម្ភសម្រាប់បេសកកម្ម៖ ចំពោះប្រាក់បេកកម្មត្រូវអនុវត្តតាមអនុក្រឹត លេខ ២១៦ . អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយយកប្រាក់បេសកកម្មប្រភេទ "ង" មិនគិតតាមមុខតំណែង និងរួមបញ្ចូលប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរ ដោយផ្អែកលើនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាគឺ៖

-ពី០គីឡូម៉ែត្រ ទៅ១០គីឡូម៉ែត្រ ចំនួន ២៤ ០០០៛០០ សម្រាប់ធ្វើដំណើរ

-លើសពី១០គីឡូម៉ែត្រ ទៅក្រោម៤០គីឡូម៉ែត្រ ចំនួន ៨០ ០០០៛០០ (សម្រាប់ធ្វើដំណើរចំនួន ២៤ ០០០៛០០ និងហូបចុកចំនួន៥៦ ០០០៛០០)

-ចាប់ពី៤០គីឡូម៉ែត្រ ឡើងទៅ ចំនួន ១៦០ ០០០៛០០ (សម្រាប់ធ្វើដំណើរចំនួន ២៤០០០៛០០ ហូបចុកចំនួន៥៦០០០៛០០ និងស្នាក់នៅចំនួន៨០ ០០០៛០០) សម្រាប់មួយនាក់ក្នុងមួយថ្ងៃ ឬមួយយប់ ។

*សក្ខីប័ត្រ៖

-ត្រូវមានលិខិតឧទ្ទេសនាម ដោយមិនចាំបាច់ប្រើប្រាស់ទិដ្ឋាការ ប៉ុន្តែត្រូវមានការបញ្ជាក់ពីអ្នកទទួលខុសត្រូវនៅទីតាំងដែលបានទៅដល់លើលិខិតឧទ្ទេសនាម

-តារាងទូទាត់ប្រាក់ឧបត្ថម្ភ និងរបាយការណ៍សកម្មភាព

•**សក្ខីប័ត្រគាំទ្រការអនុវត្តថវិកា៖** ត្រូវរក្សាទុកនៅមន្ទីរអប់រំ យុវជន និងកីឡា សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធាន លោកនាយក នាយិកាសាលារៀន ចាត់ចែងអនុវត្តថវិកា ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

សូមលោក លោកស្រីប្រធាន លោកនាយក នាយិកាសាលារៀន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ និងជានាយកគម្រោង**

បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន

**ចម្លងជូន៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទការល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ-នាយកដ្ឋានហិរញ្ញវត្ថុ